00283884

C22/5/18

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23/02/2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Huy

## អង្គបុរេជំនុំជម្រះ

PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌ លេខ:** ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៧)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ២៣ កុម្ភៈ ២០០៩

---

សាធារណៈ:

# សេចក្ដីសម្រេចលើសំណើរបស់លោក អៀង សារី សុំឲ្យកោះអញ្ជើញ អ្នកឯកទេសវេជ្ជសាស្ត្រដើម្បីផ្ដល់ភស្តុតាងនាពេលសវនាការដោយ ផ្ទាល់មាត់ស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANNONE
Pierre Olivier SUR
Elizabeth RABESANRATANA
Olivier BAHOUGNE
David BLACKMAN

**ជនត្រូវចោទ**

អៀង សារី

**សហមេធាវីការពារក្ដី**

អាង ឧត្ដម
MichaelG. ARNAVAS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 24/02/2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Huy

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C.

00283885



១. **អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") កត់សម្គាល់ឃើញ "សំណើរបស់លោក **អៀង សារី** សុំឱ្យកោះអញ្ជើញអ្នកឯកទេសវេជ្ជសាស្ត្រ ដើម្បីផ្តល់ភស្តុតាងនាពេលសវនាការដេញដោលផ្ទាល់មាត់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន" ("សំណើ") ដែលសំណើនេះត្រូវបានដាក់កាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៨។

## I. **ប្រវត្តិនីតិវិធី**

២. នៅក្នុងសំណើរបស់ខ្លួន សហមេធាវីការពារក្តីបានស្នើសុំដល់អង្គបុរេជំនុំជម្រះ "ដើម្បីកោះហៅបណ្តាវេជ្ជបណ្ឌិតនានា ដើម្បីធ្វើការសួរដេញដោលនាពេលសវនាការដេញដោលផ្ទាល់មាត់ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលមានដូចខាងក្រោមនេះ ៖

ក. វេជ្ជបណ្ឌិត Antoine LAFONT និង វេជ្ជបណ្ឌិត **លីវ ឈិន** ទៅលើខ្លឹមសារនៃរបាយការណ៍កោសលវិច្ឆ័យនានា និងការពិនិត្យសុខភាពរបស់ពួកគេលើ លោក អៀង សារី។

ខ. វេជ្ជបណ្ឌិត **នេត វណ្ណា** ទៅលើការពិនិត្យសុខភាពជាបន្តរបស់គាត់លើ លោក អៀង សារី ក្នុងឋានៈជាប្រធានមន្ទីរសុខភាពរបស់ អ.វ.ត.ក និង ទៅលើខ្លឹមសារនៃរបាយការណ៍វេជ្ជសាស្ត្រប្រចាំថ្ងៃនានារបស់គាត់ស្តីពីសុខភាពរបស់លោក អៀង សារី ដែលត្រូវបង្ហាញជូនដល់មេធាវីការពារក្តីជាមុន នៅមុនពេលសវនាការដេញដោលផ្ទាល់មាត់ និង

គ. រាល់គ្រូពេទ្យទាំងអស់នៅមន្ទីរពេទ្យកាល់ម៉ែត្រ ដែលទទួលខុសត្រូវលើការពិនិត្យសុខភាព និងការព្យាបាល លោក អៀង សារី ទៅលើរបាយការណ៍វេជ្ជសាស្ត្រនានា ដែលពួកគេបានត្រៀមរៀបចំនៅពេលដែល លោក អៀង សារី បានទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ"[1]។

[1] សំណើរបស់លោក អៀង សារី សុំឱ្យកោះអញ្ជើញអ្នកឯកទេសវេជ្ជសាស្ត្រដើម្បីផ្តល់ភស្តុតាងនាពេលសវនាការដេញដោលផ្ទាល់មាត់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៨ គ/២២/៥/១១ ("សំណើ") ទំព័រទី៥។

៣. នៅក្នុងសំណើនោះ សហមេធាវីការពារក្តីបានលើកឡើងថា "[វា]ជាការចាំបាច់ណាស់សម្រាប់រាល់វេជ្ជបណ្ឌិតទាំងអស់ដែលបានពិនិត្យសុខភាពលោក **អៀង សារី** ចាប់តាំងពីពេលដែលគាត់ត្រូវបានឃុំឃាំងដោយ អ.វ.ត.ក ត្រូវបានកោះអញ្ជើញដើម្បីសាកសួរនាពេលសវនាការដេញដោលផ្ទាល់មាត់ទៅលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ដែលគ្រោងនឹងធ្វើនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២00៩" ពីព្រោះ "ការធ្លាក់ចុះអន់ថយខាងសុខភាពរបស់លោក **អៀង សារី** មានផលប៉ះពាល់យ៉ាងច្បាស់លាស់ទៅលើការបន្តឃុំខ្លួនគាត់" និង "មានតែការអញ្ជើញអ្នកជំនាញវេជ្ជសាស្ត្រនានា និងការចោទសួរយ៉ាងហ្មត់ចត់ទៅលើអ្នកទាំងនោះអំពីរបាយការណ៍វេជ្ជសាស្ត្រនានា ដែលពួកគេបានធ្វើឡើងទាក់ទងនឹងលោក **អៀង សារី** ប៉ុណ្ណោះ ទើបបានអង្គជំនុំជម្រះមានលទ្ធភាពដើម្បីយល់ដឹងឲ្យបានពេញលេញអំពីស្ថានភាពសុខភាពរបស់លោក **អៀង សារី** និងផលប៉ះពាល់នៃស្ថានភាពសុខភាពមកលើការឃុំខ្លួនគាត់"[2]។

៤. នៅក្នុងសេចក្តីបង្គាប់ចេញថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២00៩ អង្គបុរេជំនុំជម្រះបានអញ្ជើញភាគីដែលពាក់ព័ន្ធនៅក្នុងរឿងក្តី ឲ្យដាក់សេចក្តីសន្និដ្ឋានតបចំពោះសំណើនេះ ត្រឹមថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២00៩[3]។

៥. តាមសំណើរបស់សហព្រះរាជអាជ្ញាជាតិ ប្រធានអង្គបុរេជំនុំជម្រះបានអនុញ្ញាតឲ្យមានការពន្យារពេលវេលាដែលបានកំណត់ចំពោះការដាក់ចម្លើយតបរបស់សហព្រះរាជអាជ្ញា រហូតដល់ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២00៩។

---

[2] សំណើរបស់លោក អៀង សារី សុំឲ្យកោះអញ្ជើញអ្នកឯកទេសវេជ្ជសាស្ត្រដើម្បីផ្តល់ភស្តុតាងនាពេលសវនាការដេញដោលផ្ទាល់មាត់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២00៩ គ/២២/៥/១១ ("សំណើ") ទំព័រទី២។

[3] សេចក្តីបង្គាប់ដល់ភាគីទាក់ទងនឹងសំណើរបស់ អៀង សារី សុំឲ្យកោះអញ្ជើញអ្នកឯកទេសវេជ្ជសាស្ត្រដើម្បីសវនាការដេញដោលផ្ទាល់មាត់ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២00៩ គ/២២/៥/១២ (ត្រូវបានពន្យាពេលរហូតដល់ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២00៩ ដោយប្រធានអង្គបុរេជំនុំជម្រះ តាមរយៈសំបុត្រអ៊ីម៉េលចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២00៩)។

៦. នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ "ចម្លើយរបស់ខ្លួនតបទៅនឹងសំណើរបស់លោក **អៀង សារី** សុំសាកសួរអ្នកឯកទេសវេជ្ជសាស្ត្រ នាពេលសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍នៃការបន្តការឃុំខ្លួនគាត់" ដែលនៅក្នុងចម្លើយតបនោះ សហព្រះរាជអាជ្ញាបានស្នើអង្គបុរេជំនុំជម្រះឱ្យបដិសេធចោលនូវពាក្យសុំនោះ។ សហព្រះរាជអាជ្ញាបានលើកឡើងថា សំណើសុំនោះគឺយឺតពេលហើយ និងថាមូលហេតុនានាដែលបានលើកយកមកជាសម្អាងនៅក្នុងសំណើមិនមានលក្ខណៈគ្រប់គ្រាន់ ហេតុដូច្នេះហើយមិនមានយុត្តិកម្មចំពោះការធ្វើសវនាការដេញដោលទេ។ សហព្រះរាជអាជ្ញាបានអះអាងថា សំណើសុំមានលក្ខណៈចម្រុះ ខ្វះភាពជាក់លាក់ និងគ្មានខ្លឹមសារផ្នែកអង្គហេតុ ពីព្រោះសំណើនោះមិនមានដាក់ឈ្មោះវេជ្ជបណ្ឌិតទាំងអស់ដែលត្រូវកោះហៅទេ ហើយសំណើនោះក៏មិនបានកំណត់អត្តសញ្ញាណអំពីរបាយការណ៍ជាក់លាក់ណាមួយ ឬក៏ផ្នែកណាមួយ ដែលបង្ហាញពីតម្រូវការនៃការបំភ្លឺបន្ថែមនោះឡើយ។ សហព្រះរាជអាជ្ញាក៏បានសន្និដ្ឋានថា សំណើនោះបានសុំឱ្យមានការពិនិត្យលើបញ្ហានានាដែលហួសពីវិសាលភាព នៃបណ្តឹងឧទ្ធរណ៍ ពីព្រោះសំណើនោះបានសុំនាំយកភស្តុតាងថ្មីដែលមិនបានធ្វើសក្ខីកម្មមកចំពោះមុខអង្គជំនុំជម្រះសាលាឧទ្ធរណ៍ (ដូចជាអង្គបុរេជំនុំជម្រះ ជាដើម) ដូចនេះ បានធ្វើឱ្យបរាជ័យដល់គោលដៅដ៏ល្អនៃការពិនិត្យសើរើបណ្តឹងឧទ្ធរណ៍ឡើងវិញ[4]។

៧. មកដល់ពេលនេះ ដើមបណ្តឹងរដ្ឋប្បវេណី ឬក៏មេធាវីជាតំណាងពុំទាន់បានដាក់ចម្លើយតបចំពោះសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះទាក់ទងនឹងសំណើសុំនៅឡើយទេ។

## II. ការពិនិត្យពិចារណា

៨. នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍ ទៅលើដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនរបស់ខ្លួន សហមេធាវីការពារក្តីឱ្យជនត្រូវចោទ មិនបានលើកបង្ហាញពីបញ្ហានានាគិតគូរអំពីស្ថានភាពសុខភាព

---

[4] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អៀង សារី សុំពិនិត្យលើអ្នកឯកទេសវេជ្ជសាស្ត្រ នាពេលសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍នៃការបន្តការឃុំខ្លួនគាត់ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩ គ/២២/៥/១៥ កថាខណ្ឌទី៣ដល់១៤។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE ECCC CETC

របស់ជនត្រូវចោទនោះទេ លើកលែងតែនៅក្នុងសេចក្តីយោងដ៏ខ្លីមួយនៅក្នុងកថាខណ្ឌទី៥៣ នៃសារណានោះ។ សេចក្តីយោងនេះគឺ:

"ករណីនៃការឃុំខ្លួននៅក្នុងផ្ទះ គឺត្រូវធ្វើដោយបង្ខំ ដោយយោងលើស្ថានភាពអាយុនិងសុខភាពមិនល្អរបស់លោក **អៀង សារី** ដែលជាមូលដ្ឋានសម្រាប់អង្គជំនុំជម្រះក្នុងការអនុវត្តនូវឆន្ទានុសិទ្ធដែលអនុញ្ញាតដោយវិធាន ៦៣(៣) និងបង្គាប់ឲ្យដោះលែងលោក **អៀង សារី** នៅក្រោមលក្ខខណ្ឌដែលមានកំហិតតិចនៃការឃុំខ្លួននៅក្នុងផ្ទះ"[5]។

៩. នៅក្នុងសំណើសុំឲ្យកោះអញ្ជើញសាក្សី សហមេធាវីការពារក្តីមិនបានលើកឡើងអំពីមូលហេតុដែលចង់ឲ្យមានការស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គបុរេជំនុំជម្រះនោះទេ ដែលមូលហេតុនោះអាចធ្វើឲ្យមានការសន្និដ្ឋានថា ការស្តាប់ចម្លើយសាក្សីនឹងជួយបន្ថែមនូវការគាំទ្រដល់សេចក្តីសម្អាងដែលបានលើកឡើងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី។

១០. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារក្តីមិនបានលើកឡើងនៅក្នុងសំណើសុំអំពីថាតើមានកាលៈទេសៈថ្មី ដែលបានកើតឡើងក្រោយពីបានដាក់សារណាបណ្តឹងឧទ្ធរណ៍រួចហើយ ដែលអាចធ្វើឲ្យមានយុត្តិកម្មចំពោះស្ថានភាពចាំបាច់ក្នុងការស្តាប់ចម្លើយសាក្សី នៅក្នុងអង្គជំនុំជម្រះសាលាឧទ្ធរណ៍ដែរឬទេ។ សំណើសុំរបស់ជនត្រូវចោទកត់សម្គាល់ឃើញថាគាត់បានស្ថិតនៅក្នុងមន្ទីរពេទ្យជាច្រើនដងក្នុងអំឡុងពេលដែលគាត់ត្រូវគេឃុំខ្លួនបណ្តោះអាសន្ន។ សេចក្តីយោងនេះគឺ:

"សុខភាពរបស់លោក **អៀង សារី** បានធ្លាក់ចុះជាបន្តបន្ទាប់ចាប់តាំងពីគាត់ត្រូវបានគេឃុំឃាំងនៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក តាំងពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ មក។ ចាប់តាំងពីគាត់ត្រូវឃុំឃាំងមក លោក **អៀង សារី** ត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យកាល់ម៉ែត្រចំនួន៨ដង ដែលបណ្តាលឲ្យគាត់ត្រូវសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យអស់រយៈពេលសរុបចំនួន៤៦ថ្ងៃ។ រាល់ពេលដែលលោក **អៀង សារី** ត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រ

---

[5] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៨ គ/២២/៥/១ កថាខណ្ឌទី៥៣។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE ECCC CETC

របាយការណ៍វេជ្ជសាស្ត្រមួយ ត្រូវបានគេធ្វើឡើងដោយពេលវេលាមិនគិតអំពីលក្ខខណ្ឌសុខភាព និង បញ្ញត្តិបែបបទនៃការព្យាបាល”[6]។

១១. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារក្ដីមិនបានបញ្ជាក់ថា ជនត្រូវចោទបានទៅកាន់មន្ទីរពេទ្យ នៅក្រោយពេលដែលបានដាក់សារណាបណ្ដឹងឧទ្ធរណ៍នោះទេ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សំណើដែលសហមេធាវីការពារក្ដីបានដាក់ជូន នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ រួមមានព័ត៌មានទាំងនោះ ដោយមិនមានការបញ្ជាក់ឱ្យបានច្បាស់លាស់។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញទៀតថា សំណើនេះរួមមានព័ត៌មានដែលផ្ទុយទៅនឹងសំណើចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៩។[7]

១២. អង្គបុរេជំនុំជម្រះក៏បានកត់សម្គាល់ឃើញផងដែរថា សំណុំរឿងមិនមានព័ត៌មានដែលថាជនត្រូវចោទបានទៅកាន់មន្ទីរពេទ្យ ក្រោយពេលដែលបានដាក់សារណាបណ្ដឹងឧទ្ធរណ៍នោះទេ។ នៅក្នុងសំណុំរឿងមានកំណត់ហេតុនៃការសាកសួរជនត្រូវចោទទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួន ដែលបានធ្វើឡើងកាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៨។ នៅក្នុងការសាកសួរនេះ សហមេធាវីអន្តរជាតិបានថ្លែងក្នុងនាមជនត្រូវចោទ ដូចខាងក្រោមនេះ ៖

> “ខ្ញុំបានជួបជាមួយកូនក្ដីរបស់ខ្ញុំពីម្សិលមិញ គាត់បានប្រាប់ខ្ញុំថាសុខភាពរបស់គាត់ល្អគ្រប់គ្រាន់ដែលអាចចូលរួមក្នុងការសាកសួរដែលធ្វើនៅទីនេះបាន។ ហើយខ្ញុំក៏បានពិភាក្សាជាមួយគ្រូពេទ្យនៅមន្ទីរឃុំឃាំងដែរ គ្រូពេទ្យបាននិយាយថាស្ថានភាពសុខភាពរបស់ជនត្រូវចោទគឺមានលំនឹង ហើយគាត់ត្រូវបានតាមដានពិនិត្យជាទៀងទាត់។ ដូច្នេះ ការថែទាំសុខភាពដែលបានផ្ដល់ដល់កូនក្ដីរបស់ខ្ញុំគឺមានលក្ខណៈគ្រប់គ្រាន់ហើយ។

---

[6] សំណើរបស់លោក អៀង សារី សុំឱ្យកោះអញ្ជើញអ្នកឯកទេសវេជ្ជសាស្ត្រដើម្បីផ្ដល់ភស្តុតាងនាពេលសវនាការដេញដោលផ្ទាល់មាត់ស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៩ គ/២២/៥/១១ (“សំណើ”) ទំព័រទី៣។

[7] សំណើរបស់លោក **អៀង សារី** សុំឱ្យដាក់បញ្ចូលបន្ថែមនូវរបាយការណ៍វេជ្ជសាស្ត្ររបស់វេជ្ជបណ្ឌិត PAULUS FALKE ទៅក្នុងសំណុំរឿង និងសំណើសុំអនុញ្ញាតឱ្យវេជ្ជបណ្ឌិត PAULUS FALKE ដើម្បីផ្ដល់ភស្តុតាងតាមរយៈការផ្សាយបន្តផ្ទាល់តាមរូបភាពវីដេអូ (Videolink) នាពេលសវនាការ ថ្ងៃទី២៦ កុម្ភៈ ២០០៩, ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ C/22/5/16។



FRE TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

ទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួនវិញ កូនក្ដីរបស់ខ្ញុំបានកត់សម្គាល់ឃើញថា ម្ហូបអាហារដែលត្រូវបានផ្ដល់ឲ្យគាត់មិនស្របទៅតាមតម្រូវការរបស់គាត់ទេ។ ជាពិសេស គាត់បាននិយាយថា គាត់មិនបរិភោគសាច់ជ្រូកទេពីព្រោះវាមានជាតិខ្លាញ់ [ច្រើនពេក] ឬមិនចម្អិនបានឆ្អិនល្អ។ ក្រៅពីបញ្ហាម្ហូបអាហារ យើងមិនមានយោបល់អ្វីផ្សេងទៀតជម្រាបជូនទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួនទេ”[8]។

១៣. នៅពេលកំពុងធ្វើការសាកសួរ មិនមានសំណើណាមួយដែលស្នើដោយសហមេធាវីការពារក្ដីឲ្យមានការស្ដាប់ចម្លើយអ្នកឯកទេសនោះឡើយ ហើយសហមេធាវីក៏មិនមានធ្វើការតវ៉ាអំពីលក្ខខណ្ឌនៃការឃុំខ្លួនដែលពាក់ព័ន្ធនឹងស្ថានភាពសុខភាពរបស់ជនត្រូវចោទនោះដែរ។

១៤. អង្គបុរេជំនុំជម្រះបានរកឃើញថា មិនមានកាលៈទេសៈថ្មីណាមួយបានលេចេញនោះទេ តាំងតែការដាក់បណ្ដឹងឧទ្ធរណ៍ ដែលបណ្ដឹងឧទ្ធរណ៍នោះហាក់ដូចជាបង្ហាញពីការប្រញាប់ ឬភាពចាំបាច់ក្នុងការស្ដាប់ចម្លើយអ្នកឯកទេស។ ដោយសារតែសហមេធាវីការពារក្ដីមិនបានរកឲ្យឃើញនូវកាលៈទេសៈ ដែលពាក់ព័ន្ធស្ថានភាពសុខភាពរបស់ជនត្រូវចោទ ដែលមានលក្ខណៈផ្ទុយទៅនឹងអ្វីដែលអ្នកឯកទេសបានសន្និដ្ឋានរួចហើយនោះ វាមិនមានយុត្តិកម្មណាមួយដែលត្រូវបង្ហាញជូនដល់អង្គបុរេជំនុំជម្រះ ដើម្បីឲ្យអង្គបុរេស្ដាប់ចម្លើយអ្នកឯកទេសទាក់ទងនឹងបណ្ដឹងឧទ្ធរណ៍នោះឡើយ។ អង្គបុរេជំនុំជម្រះនឹងអនុញ្ញាតឲ្យសហមេធាវីលើកនូវអំណះអំណាងថ្មីនាពេលសវនាការខាងមុខ ហើយនៅពេលនេះសហមេធាវីអាចកែលម្អរសំណើសម្រាប់ដាក់ម្ដងទៀត បើសិនជាសហមេធាវីអាចធ្វើឲ្យសំណើមានលក្ខណៈច្បាស់លាស់។

១៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីបានបន្ថែមថា ខ្លួនមានសិទ្ធិដែលគ្មានដែនកំណត់ក្នុងការសួរដេញដោលអ្នកឯកទេស។ អំណះអំណាងនេះត្រូវបានលើកឡើងដោយយោងទៅលើយុត្តិសាស្ត្ររបស់តុលាការដទៃទៀត ព្រមទាំងបញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធនឹងតុលាការ

---

[8] កំណត់ហេតុនៃការសាកសួរទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួន ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៨ គ៤៤ ទំព័រទី២។

ទាំងនោះ។ វិធានច្បាប់ និងយុត្តិសាស្ត្រទាំងនេះសំដៅដល់ការសួរដេញដោលអ្នកឯកទេសរបស់ភាគីម្ខាងទៀត តែមិនមែនអ្នកឯកទេសដែលចាត់តាំងដោយតុលាការនោះទេ។

១៦. អង្គបុរេជំនុំជម្រះពិចារណាឃើញថាមានលក្ខណៈសមរម្យក្នុងការបដិសេធសំណើសុំនោះ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ៖**

**បដិសេធចោល**សំណើសុំឱ្យកោះអញ្ជើញអ្នកឯកទេសវេជ្ជសាស្ត្រ ដើម្បីផ្តល់ភស្តុតាង នាពេលសវនាការដេញដោលផ្ទាល់មាត់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន។ ៗ៕

ភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩
ប្រធានអង្គបុរេជំនុំជម្រះ

ប្រាក់ គឹមសាន